# សេចក្តីសង្ខេបនៃដំណើរការបណ្តឹងភាគីទីបី

អេឌីឌាស មានគោលការណ៍និងការអនុវត្តន៍និរន្តរភាពផ្ទៃក្នុង ព្រមទាំងស្តង់ដារការងារដែលក្រុមហ៊ុនផ្គត់ផ្គង់ អ្នកទទួលបានអាជ្ញាប័ណ្ណ ភ្នាក់ងារ និងអ្នកផ្តល់សេវាផ្សេងទៀតត្រូវតែអនុវត្តតាម។

រាល់ការអនុវត្តន៍ផ្ទុយពីស្តង់ដារ ឬជាសញ្ញាណណាមួយ ឬការអនុវត្តន៍ជាក់ស្តែងដែលរំលោភសិទ្ធិមនុស្ស ហើយមានទំនាក់ទំនងទៅនឹងប្រតិបត្តិការ ការផលិត ឬសោវាកម្មរបស់អេឌីឌាស អាចលើកជាបណ្តឹងឡើងតាមរយៈបណ្តឹងតវ៉ាភាគីទីបីដែលចែងដូចខាងក្រោមៈ

**តើនរណាអាចធ្វើបណ្តឹងបាន?**

បុគ្គល ឬអង្គភាពណាមួយដែលរងផលប៉ះពាល់ដោយផ្ទាល់ពីបញ្ហា ឬអង្គការដែលតំណាងឱ្យបុគ្គល ឬសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ណាមួយ អាចធ្វើជាពាក្យបណ្តឹងបាន។

**តើបណ្តឹងមានដំណើរការយ៉ាងដូចម្តេច?**

ពាក្យបណ្តឹងគួរមានមូលដ្ឋានច្បាស់លាស់ ។ និយោជិតដែលលើកជាបណ្តឹងហើយធ្វើការក្នុងរោងចក្រដែលផលិតឲ្យអេឌីឌាស គួរប្រើលេខទូរស័ព្ទអេឌីឌាសដែលបានបិតផ្សាយនៅកន្លែងការងារ។ រាល់បណ្តឹងទាំងអស់អាចផ្ញើរសារទៅកាន់ sustainability@adidas-Group.com ហ្វាក់ ឬសំបុត្រ ឬទូរស័ព្ទនៅទំព័រទី២។

ពាក្យបណ្តឹងគួរតែភ្ជាប់មកជាមួយព័ត៌មានពាក់ព័ន្ធទាំងអស់ និងពន្យល់ពីតម្រូវការ។ ពាក្យបណ្តឹងមិនចាំបាច់សរសេរជាភាសាអង់គ្លេសនោះទេ គឺអាចសរសេរជាភាសាជាតិខ្លួនផ្ទាល់បាន ។ ពាក្យបណ្តឹងនឹងត្រូវដោះស្រាយដោយបើកចំហរ និងមានតម្លាភាព លើកលែងតែក្នុងករណីដែលមានហានិភ័យនៃការសងសឹក ទើបការដោះស្រាយបណ្តឹងមិនធ្វើជាសាធារណៈ។

**ជំហានក្នុងការដោះស្រាយពាក្យបណ្តឹងរួមមាន:**

1. ការទទួលពាក្យបណ្តឹង
2. ការវាយតម្លៃហេតុផលនៃបណ្តឹង វិធីដែលអេឌីឌាសដោះស្រាយក្នុងករណីដែលបណ្តឹងត្រូវបានទទួលយក
3. ករណីដែលបណ្តឹងត្រូវបានទទួលយក ព័ត៌មានទាំងអស់នឹងត្រូវត្រួតពិនិត្យឡើងវិញដោយប្រុងប្រយ័ត្នដោយផ្នែកកិច្ចការសង្គមនិងបរិស្ថាន SEA ។ ការត្រួតពិនិត្យអាចអាចប្រើពេលមួយសប្តាហ៍ ឬច្រើនជាងមួយសប្តាហ៍។
4. ការឆ្លើយតបនៃពាក្យបណ្តឹងនឹងធ្វើឡើងដោយផ្អែកលើការរកឃើញពីការពិនិត្យឡើងវិញនៃពាក្យបណ្តឹង។
5. ក្នុងករណីចំបាច់SEA នឹងចុះអង្កេតដោយផ្ទាល់ ឬក៏ជ្រើសយកភាគី៣ដើម្បីចុះអង្កេត ។ គោលបំណងក្នុងការចុះអង្កេត គឺដើម្បីប្រមូលព័ត៌អោយបានគ្រប់គ្រាន់ដើម្បីដោះស្រាយបណ្តឹងដោយផ្អែកលើអង្គហេតុពេញលេញនៃបណ្តឹង។

6. ក្នុងដំណាក់កាលនេះ ពាក្យបណ្តឹងអាចដោះស្រាយតាមរយៈការព្រមព្រៀងទៅវិញទៅមក។ បើសិនគ្មានការព្រមព្រៀងរវាងភាគីនោះទេ អេឌីខាសនឹងធ្វើការសំរេចលទ្ធផលនៃបណ្តឹង។
7. ក្នុងករណីដែលអេឌីខាស ជាអ្នកបណ្តាល ឬចូលរួមដោយផ្ទាល់ចំពោះការរំលោភបំពាន យើងខ្ញុំនឹងស្វែងរកការបង្ការ ឬការកាត់បន្ថយឱកាសនៃផលប៉ះពាល់ ។
8. ក្នុងករណីផលប៉ះពាល់អវិជ្ជមានបានកើតឡើង អេឌីខាសនឹងចូលរួមយ៉ាងសកម្មនៅក្នុងការដោះស្រាយ។ ក្នុងករណីអេឌីខាស មិនមែនជាអ្នកបណ្តាលឱ្យ ឬរួមចំណែកដោយផ្ទាល់ដល់ការរំលោភបំពាន យើងខ្ញុំនឹងលើកទឹកចិត្តឱ្យដៃគូអាជីវកម្មដែលបានបណ្តាល ឬចូលរួមចំណែកទៅនឹងផលប៉ះពាល់ ធ្វើការការពារ ឬកាត់បន្ថយការកើតមានឡើងវិញនៃផលប៉ះពាល់ ។

យោងទៅលើភាពស្មុគស្មាញនៃបណ្តឹង ពាក្យបណ្តឹងមួយអាចត្រូវចំណាយពេលពី3សប្តាហ៍Mឬច្រើនជាងនេះ ដើម្បីធ្វើការវាយតម្លៃ ស៊ើបអង្កេត និងបន្តដំណើរការ មុនពេលឈានចូលកិច្ចព្រមព្រៀងពីបន្ថែមទៀតមុនពេលអាចទៅដល់កិច្ចព្រមព្រៀងពីការកែតំរូវ។

## សកម្មភាពត្រួតពិនិត្យ

អាស្រ័យលើប្រភេទនៃការកែតំរូវដែលបានព្រមព្រៀង អេឌីខាសនឹងស្វែងរកការព្រមព្រៀងលើវិធីត្រួតពិនិត្យដើម្បីធានាថាការកែតំរូវ ក្នុងកាលកំណត់ដែលបានព្រមព្រៀងគ្នា។ ផ្នែកអេឌីខាសSEA នឹងត្រួតពិនិត្យនូវលទ្ធផលបានព្រមព្រៀង ឬនឹងចាត់តាំងភាគីទីបីមួយដែលទុកចិត្តដើម្បីត្រួតពិនិត្យ។

ក្នុងករណីបុគ្គល ឬអង្គការដែលគិតថាពួកគេបានរងការគំរាមកំហែង ឬក៏រងការសងសឹក ដោយសារតែការដាក់ពាក្យបណ្តឹងមកកាន់អេឌីខាស ពួកគាត់អាចទំនាក់ទំនងមកកាន់ SEA និងផ្តល់នូវព័ត៌មានលម្អិតដែលបានកើតឡើង។ SEA នឹងធ្វើការស៊ើបអង្កេត ក្នុងករណីដែលមានភស្តុតាងច្បាស់លាស់ នឹងរៀបចំអោយការកែតំរូវនូវស្ថានភាពនេះ ។

## បណ្តឹងបន្ត

ប្រសិនបើភាគីណាមួយមិនពេញចិត្តនឹងរបៀបដែលដោះស្រាយបណ្តឹង ពួកគេអាចលើកឡើងមកផ្នែកSEA។ SEA នឹងពិនិត្យករណីនេះហើយទាក់ទងទៅផ្នែកអ្នកប្រឹក្សាទូទៅរបស់អេឌីខាស ធ្វើការសំរេចចិត្តជាចុងក្រោយ។

## វិធីផ្សេងទៀតដើម្បីតវ៉ា

បុគ្គលឬអង្គការដែលអាចប្រើបណ្តាញឯករាជ្យផ្សេងទៀតដើម្បីប្តឹងតវ៉ារួមមានThird Party Complaint Process of the Fair Labor Association (FLA) និង OECD National Contact Point for Germany.

## សិទ្ធិស្របច្បាប់

បុគ្គល ក្រុម ឬសហគមន៍ដែលដាក់ពាក្យបណ្តឹងមកអេឌីខាស នៅតែមានសិទ្ធិស្របច្បាប់ និងដាក់ពាក្យសុំទៅតុលាការ ឬរដ្ឋបាលដែលទទួលដោះស្រាយក្នុងស្រុក។ ប្រសិនបើជាបញ្ហាផ្នែកច្បាប់ ឬការបកស្រាយផ្លូវច្បាប់គឺជាធាតុសំខាន់មួយនៃការតវ៉ា ភាគីគួរតែអនុវត្តតាមយន្តការច្បាប់ជាមុន។

## ទំនាក់ទំនងមកកាន់អេឌីដាស

| អឺរ៉ុប | អាហ្វ្រិក ភាគខាងកើតណ្តាល<br>អាស៊ីប៉ាស៊ីហ្វិក | អាមេរិក |
|---|---|---|
| adidas<br>Social & Environmental Affairs<br>Adi-Dassler-Straße 1<br>91074 Herzogenaurach<br>Germany<br><br>Attention: Mr Frank Henke | adidas<br>Social & Environmental Affairs<br>10 Floor, Cityplaza Four<br>12 Taikoo Wan Road<br>Hong Kong<br><br>Attention: Mr William Anderson | adidas<br>Social & Environmental Affairs<br>5055 North Greeley Avenue<br>OR 97217<br>USA<br><br>Attention: Mr Gregg Nebel |
| Global Director, Social & Environmental Affairs<br><br>Phone: +49 (0) 9132 / 84 - 0<br>Fax: +49 (0) 9132 / 84 - 3242 | Vice President, Social & Environmental Affairs<br>Phone: +852 2302 8654<br>Fax: +852 2302 8875 | Vice President, Social & Environmental Affairs<br><br>Phone: +1 971 234 4905 |